**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

# ជាម ច័ន្ទនី ត្រូវការការលើកទឹកចិត្ត

ឯកឧត្តម ជាម ច័ន្ទនី ស្ថិតនៅក្នុងមន្ទីរឃុំឃាំងតុលាការយោធា អស់រយៈពេល៤ខែហើយ ពីបទចោទប្រកាន់ដោយអយុត្តិធម៌ពីសំណាក់អាជ្ញាធរ ហើយរហូតមកដល់ពេលនេះ តុលាការមិនបានធ្វើការស៊ើបអង្កេត ឬ ចាត់ការករណីនេះនៅឡើយ ។ ការមិនចាត់ការនេះ គឺក្នុងគោលបំណងបំបាក់ស្មារតីឯកឧត្តម ជាម ច័ន្ទនី ឬចង់ឲ្យឯកឧត្តម ជាម ច័ន្ទនី ប្តូរគោលជំហរផ្សេង ក្នុងគោលដៅបង្កើតលេសដើម្បីបង្ក្រាប ឬកំចាត់លោកប្រធាន សម រង្ស៊ី ចេញពីឆាកនយោបាយ ។ ពួកអ្នកកាន់អំណាចនឹងសប្បាយចិត្ត នៅពេលណាដែលឯកឧត្តម ជាម ច័ន្ទនី អស់សង្ឃឹមក្នុងការតស៊ូ ដើម្បីសេរីភាព យុត្តិធម៌ និងប្រជាធិបតេយ្យ ។

ដូច្នេះ ដើម្បីឲ្យឯកឧត្តម ជាម ច័ន្ទនី មានសេចក្តីសង្ឃឹមជានិច្ចក្នុងការតស៊ូ ខ្ញុំសូមអំពាវនាវដល់ជនរួមជាតិដែលស្រឡាញ់យុត្តិធម៌ សេរីភាព និងប្រជាធិបតេយ្យ ជួយលើកទឹកចិត្តឯកឧត្តម ជាម ច័ន្ទនី តាមរយៈការឧបត្ថម្ភជាស្មារតី សំភារៈ និងថវិកា តាមលទ្ធភាព និងសមានចិត្ត ។ ឯកឧត្តម ជាម ច័ន្ទនី ត្រូវការចំណាយរៀងរាល់ខែយ៉ាងតិច៣០០ដុល្លារអាមេរិក សំរាប់ការហូបចុក និងការដោះស្រាយផ្សេងៗនៅក្នុងពន្ធនាគារ ហើយមិនតែប៉ុណ្ណោះមានមនុស្សមួយចំនួនកំពុងស្ថិតនៅក្នុងបន្ទុករបស់ក្រុមគ្រួសារឯកឧត្តម ជាម ច័ន្ទនី ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូនសប្បុរសជនដែលបានឧបត្ថម្ភឯកឧត្តម ជាម ច័ន្ទនី និងក្រុមគ្រួសារ នាពេលកន្លងមក ។

ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនដល់បងប្អូនសប្បុរសជនទាំងអស់ ដែលបានជួយផ្តល់ជាវិភាគទានជាសម្ភារៈក្តី ជាថវិកាក្តី ដើម្បីជួយលើកទឹកចិត្តឯកឧត្តម ជាម ច័ន្ទនី និងក្រុមគ្រួសារ ហើយនិងសូមជូនពរឲ្យជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការ គឺ : អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

*រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៥*

**អេង ឆៃអ៊ាង**

**តំណាងរាស្ត្រមណ្ឌលបាត់ដំបង**

**និងជាអគ្គលេខាធិការគណបក្ស សម រង្ស៊ី**